ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពីពិធីចុះហត្ថលេខា

## លើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង

## រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

នាព្រឹកថ្ងៃច័ន្ទ ១១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង លោក Yuichi SUGANO ប្រធានតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំនៅកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្រុងតាខ្មៅ (The Project for the Expansion of Water Suppy System in Ta Khmau) ដែលមានទឹកប្រាក់ចំនួន ៣ ៤២១ លានយ៉េនជប៉ុន (ប្រមាណជា ៣២ លានដុល្លារអាមេរិក)។

កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ដែលបានចុះហត្ថលេខានៅពេលនេះ គឺជាឯកសារគតិយុត្តិមួយទៀត បន្ទាប់ពីលិខិតប្តូរសារដែលបានចុះហត្ថលេខា កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ កន្លងទៅរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ដែលអាចនាំឱ្យឈានទៅដល់ការអនុវត្តនីតិវិធីបន្តបន្ទាប់ទៀតសម្រាប់ការអនុវត្តគម្រោងជាក់ស្តែង។

គម្រោងនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាពក្នុងក្រុងតាខ្មៅតាមរយៈ (១)-ការសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតដែល មានសមត្ថភាពផលិតទឹកស្អាតបាន ៣០ ០០០ ម៣ ក្នុងមួយថ្ងៃ (២)-ការសាងសង់ស្ថានីយ៍បូមទឹកឆៅ និងបំពង់មេនាំទឹកឆៅ (៣)-ការសាងសង់បរិក្ខាសម្រាប់ចែកចាយទឹកស្អាត និង (៤)-ការបំពាក់ប្រព័ន្ធ SCADA សម្រាប់តាមដាន និងបញ្ជាដំណើរការរបស់រោងចក្រ ព្រមទាំងការផ្ទេរបច្ចេកវិទ្យាសម្រាប់ប្រតិបត្តិការ និងការថែទាំរោងចក្រដោយប្រើបទពិសោធន៍ និងចំណេះដឹងពីប្រទេសជប៉ុន។ បច្ចុប្បន្ន ទឹកស្អាតដែល

កំពុងប្រើប្រាស់ក្នុងក្រុងតាខ្មៅ គឺត្រូវបានផ្គត់ផ្គង់ជាចម្បងពីរាជធានីភ្នំពេញ។ ដូច្នេះ គម្រោងនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើង មិនត្រឹមតែសេវាផ្គត់ផ្គង់ទឹកស្អាត នៅក្នុងក្រុងតាខ្មៅ និងតំបន់ជុំវិញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយការផ្គត់ផ្គង់ទឹកស្អាតពីរាធានីភ្នំពេញផងដែរ។ ការសាងសង់គម្រោងនេះនឹងចំណាយរយៈពេលចំនួន ២៩ខែ ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២៣។

គម្រោងហិរញ្ញប្បទានឥតសំណងនេះ គឺជាគម្រោងទី ១២ ចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលជប៉ុន តាមរយៈ JICA បានផ្តល់ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត ហើយក៏ជាហិរញ្ញប្បទានឥតសំណងលើកទី៦ ផងដែរ ដែលបានផ្តល់ដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ទន្ទឹមនឹងនេះ បរិក្ខាផ្គត់ផ្គង់ទឹកស្អាតជាច្រើនកន្លែងត្រូវបានសាងសង់ឡើងដោយប្រើប្រាស់ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានជាប្រាក់យ៉េនជប៉ុន នៅតាមបណ្តាខេត្តផ្សេងៗ ដូចជា ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងរាជធានីភ្នំពេញ។

ក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត JICA តែងតែប្រកាន់ភ្ជាប់នូវវិធីសាស្ត្រអភិវឌ្ឍដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងការពង្រឹងភាពជាដៃគូជាយុទ្ធសាស្ត្ររយៈពេលយូរជាមួយរាជរដ្ឋាភិបាលកម្ពុជា។

គម្រោងនេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជួយដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេច **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ**លើវិស័យផ្គត់ផ្គង់ទឹកស្អាត ១០០ ភាគរយ នៅក្នុងទីប្រជុំជនត្រឹមឆ្នាំ ២០២៥ តាមរយៈការគាំទ្រដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលឆ្លើយតបយ៉ាងជាក់ច្បាស់ទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់កម្ពុជាក្នុងការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**ស្របទៅនឹងមុំទី១ នៃចតុកោណទី៤ ដូចមានចែងក្នុងឯកសារយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។**


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់÷

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ **លោក រៀម ឧត្តម** តាមរយៈអ៊ីម៉ែល utdom.mef@gmail.com
- ការិយាល័យ JICA ប្រចាំកម្ពុជា÷ **លោក សាយ បូរ៉ា** មន្រ្តីកម្មវិធីជាន់ខ្ពស់ តាមរយៈអ៊ីម៉ែល saybora.cm@jica.go.jp


*******************